**ជនដែលត្រូវបានការពារ (protected persons)**

ពាក្យនេះ ត្រូវបានប្រើក្នុងច្បាប់មនុស្សធម៌អន្តរជាតិ សំដៅលើជនស៊ីវិល (civilian) អ្នកជំងឺក្នុងជួរកងកម្លាំង អ្នកជំងឺក្នុងកប៉ាល់របស់កងកម្លាំងដែលរងការខូចខាត ឈ្លើយសឹក (prisoner of war) ឬជនដែលទម្លាក់អាវុធ ឬលែងចូលរួមដោយផ្ទាល់ក្នុងជម្លោះ (*hors de combat*) ។

ជនស៊ីវិល ដែលស្ថិតនៅក្នុងប្រទេសជាភាគីជម្លោះ ដែលមិនមានសញ្ជាតិនៃប្រទេសនោះ។ ទោះបីជាយ៉ាងនេះក្តី តាមយុត្តិសាស្ត្រតុលាការ ការទាមទារនូវចំណងផ្លូវការ (formal bond) តាមរយៈសញ្ជាតិ លែងមានភាពចាំបាច់ខ្លាំងហើយ។ ទំនាក់ទំនងធន់ល្មម (substantial relation of allegiance) គឺគ្រប់គ្រាន់ក្នុងការទទួលបាននូវការការពារ (*Tadic*, IT-94-1, 1999, S. 166)។

ការប្រព្រឹត្តលើជនត្រូវបានការពារ ពីដើមមក ត្រឹមតែជាការប្រព្រឹត្តបែបមនុស្សធម៌ (human treatment)។ ក៏ប៉ុន្តែក្រោយមក វាត្រូវបានពង្រីកបន្ថែម រាប់បញ្ចូល ការហាមឃាត់នូវការវាយប្រហារមិនរើសមុខ (indiscriminate attack)។ បុគ្គលិកផ្នែកមនុស្សធម៌ (humanitarian relief personnel) ឬ អ្នកសារព័ត៌មាន ក៏ត្រូវបានរាប់បញ្ចូលក្នុងក្រុម ដែលត្រូវបានការពារផងដែរ។

ជនត្រូវបានការពារ នឹងបាត់ឋានៈរបស់ខ្លួន នាពេល ខ្លួនបានប្រព្រឹត្តទង្វើគ្រោះថ្នាក់ដល់សត្រូវ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp.473-474)។

**ខ្លឹមសារបន្ថែម៖** ការប្រព្រឹត្ត ដូចជាសម្លាប់ជនត្រូវបានការពារ ជាបទឧក្រិដ្ឋកម្មសង្គ្រាម (war crime)។ នៅក្នុងចំណោមជនស៊ីវិល បើមានកងកម្លាំងប្រដាប់អាវុធខ្លះ នៅក្នុងនោះ ក្រុមទាំងមូល ត្រូវបានរាប់ថាជាក្រុមជនស៊ីវិល។